# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1233

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (ផ្នែកនេសាទ)

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/07/19 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/25 |

៣. ចំណាយគម្រោងសរុប $40,080,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | FiA |
| អង្គភាពទទួលខុសត្រូវ | ជលផល |

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការអភិវឌ្ឍទីផ្សារការងារ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

១- ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អការគ្រប់គ្រង អភិរក្ស និងការគោរពច្បាប់ស្តីពីជលផល និងបទប្បញ្ញត្តិនានានៅក្នុងដែននេសាទទឹកសាប និងសមុទ្រ ក្នុងបរិបទនៃការគ្រប់គ្រងរួមគ្នា និងវិធីសាស្រ្តគ្រប់គ្រងធនធានជលផលតាមបែបប្រព័ន្ធអេកូឡូស៊ីដែលបានអនុម័តដោយប្រទេស និងកំពុងបន្តការអនុវត្តជំណើការវិមជ្ឈការ (ស្របទៅតាមសសរស្តម្ភទី១ និងទី៤ នៃក្របខណ្ឌផែនការយុទ្ធសាស្រ្តវិស័យជលផល)

២- គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងការកែច្នៃផល ផលិតផលជលផល ដែលរួមចំណែកដល់ការបង្កើតចំណូល និងការបង្កើតការងារ (ស្របទៅតាមសសរស្តម្ភទី៣ នៃក្របខ័ណ្ឌផែនការយុទ្ធសាស្រ្តវិស័យជលផល)

៣- ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងបរិស្ថានរបស់សហគមន៍នេសាទនៅតំបន់ទន្លេសាប និងតំបន់ឆ្នេរ និងកាត់បន្ថយគម្លាតសេដ្ឋកិច្ច និងសង្គមជាមួយនឹងប្រជាពលរដ្ឋកម្ពុជាដទៃទៀត។

### ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី Fisheries

Fisheries

Fisheries

១២. ទីតាំងអនុវត្តគម្រោង ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

គ្រប់ខេត្តក្រុង,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

គោលបំណងរួមរបស់គម្រោងគឺ ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព ភាពធន់ទៅនឹងអាកាសធាតុ និងបរិយាប័ន្ននៃធនធានជលផលទឹកសាប និងសមុទ្រនៅក្នុងប្រទេសកម្ពុជា ដោយបានចូលរួមចំណែកនៅក្នុងការសម្រេចបាននូវគោលបំណងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល (SPF 2015 - 2024) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេល០៥ឆ្នាំ (ASDP) ។ កម្មវិធីនេះនឹងរួមចំណែកធ្វើឱ្យមានភាពប្រសើរឡើងនៅក្នុងផ្នែកនានាដែលពាក់ព័ន្ធនឹងសកម្មភាពការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត (Illegal, Unregulated and Unreported-IUU) ។

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

គោលបំណងទី១៖ អភិរក្ស គ្រប់គ្រង និងអនុលោមតាមច្បាប់ និងបទបញ្ញត្តិ

សូចនាករទី១៖ ការអនុវត្ត និងគោរពតាមច្បាប់ និងបទបញ្ញត្តិជលផល ដែលបានធ្វើឲ្យប្រសើរឡើងដល់ធនធានជលផលទឹកសាប

សូចនាករទី២៖ ការការពារទីជម្រកធនធានជលផលទឹកសាប

សូចនាករទី៣៖ ការអនុវត្ត និងការគោរពច្បាប់ និងបទបញ្ញត្តិជលផល គឺបានធ្វើឲ្យប្រសើរឡើងដល់ធនធានជលផលសមុទ្រ

សូចនាករទី៤៖ លើកកម្ពស់អត្ថិភាពព័ត៌មាន និងទិន្នន័យដែលជាព័ត៌មានចាំបាច់សម្រាប់ការគ្រប់គ្រង និងបង្កើតគោលនយោបាយជលផល

គោលបំណងទី២៖ គាំទ្រដល់សហគមន៍ (សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី)

សូចនាករទី៥៖ បង្កើនសមត្ថភាពរបស់សហគមន៍ដើម្បីចូលរួមចំណែកនៅក្នុងសហគ្រប់គ្រង/ការគ្រប់គ្រងរួមគ្នា

គោលបំណងទី៣៖ សុវត្ថិភាពនៃត្រី និងផល ផលិតផលជលផល

សូចនាករទី៦៖ ពង្រឹងការត្រួតពិនិត្យផ្លូវការលើផលត្រី និងផល ផលិតផលជលផល

គោលបំណងទី៤៖ ពង្រឹងសមត្ថភាពស្ថាប័ន

សូចនាករទី៧៖ បង្កើនថវិការាជរដ្ឋាភិបាលកម្ពុជាជូនដល់វិស័យជលផល

សូចនាករទី៨៖ ការគ្រប់គ្រងធនធានមនុស្សបានប្រសើរឡើង

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

កម្មវិធី CAPFISH-Capture គឺជាការចូលរួមចំណែករបស់សហភាពអឺរ៉ុប ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិស័យជលផលដោយរួមបញ្ចូលជាមួយការគាំទ្របន្ថែមដើម្បីផ្តល់ជំនួយបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពរបស់អ្នកពាក់ព័ន្ធនឹងការគ្រប់គ្រង និងជួយដល់វិស័យនេះ។ ដើម្បីធ្វើការងារនេះ ការគាំទ្របន្ថែមនឹងផ្តោតសំខាន់ទៅលើអ្នកពាក់ព័ន្ធសំខាន់ៗដែលរួមមាន៖ ១- រដ្ឋបាលជលផលថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ ការដាក់ឲ្យអនុវត្តច្បាប់ និងបទបញ្ញត្តិ ដើម្បីធានាដល់ការអភិរក្សតំបន់ និងជម្រកត្រីធំៗ និងការត្រួតពិនិត្យវឌ្ឍនៈភាពនៃវិស័យនេះ។ ៣- អង្គការ សហគមន៍ ដែលត្រូវបានពង្រឹងថានឹងដើរតួនាទីកាន់តែសំខាន់នៅក្នុងការគ្រប់គ្រងរួមគ្នារវាងធនធានជលផលទឹកសាប និងតំបន់ឆ្នេរ និងជាពិសេសចូលរួមនៅក្នុងសកម្មភាពអភិរក្ស ការពារ និងការឃ្លាំមើល និង ៤- វិស័យឯកជនដែលពាក់ព័ន្ធជាមួយនឹងសហគមន៍នៅក្នុងការងារកែច្នៃផល ជលផល។ វិស័យឯកជនក៏នឹងគាំទ្រផងដែរដល់ការបង្កើតយន្តការដ៏មានប្រសិទ្ធភាពក្នុងការសម្របសម្រួលអន្តរវិស័យ និងជំរុញការអភិវឌ្ឍប្រកបដោយភាពសុខដុម និងផ្តល់ភាពអង់អាចដល់ស្ត្រីនៅក្នុងសហគមន៍ និង MSMEs ក្នុងវិស័យជលផល។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកដែលនឹងទទួលផលពីគម្រោងនេះគឺប្រជាពលរដ្ឋកម្ពុជាទាំងអស់ដែលបានប្រើប្រាស់ធនធានជលផលទាំងនៅទឹកសាប និងនៅសមុទ្រ។ គម្រោងនេះរួមចំណែកយ៉ាងសំខាន់ទៅលើសមិទ្ធិផលវឌ្ឍនភាពនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព លុបបំបាត់ភាពអត់ឃ្លាន សម្រេចបាននូវសន្តិសុខស្បៀង លើកកម្ពស់អាហារូបត្ថម្ភ ព្រមទាំងលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាព និងការប្រើប្រាស់ធនធានសមុទ្រឲ្យបានយូរអង្វែង។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **គ្មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទានចាប់ផ្តើម** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះមិនមានផលប៉ះពាល់អវិជ្ជមានទៅដល់ផ្នែកបរិស្ថាន និងសង្គមនោះទេ ប៉ុន្តែគម្រោងនេះនឹងជួយបង្កើនប្រាក់ចំណូលដល់គ្រួសារក្រីក្រតាមតំបន់ជនបទ។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

| | |
|---|---|
| តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? | **មាន** |
| ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស | **ការត្រៀម** |

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការលុបបំបាត់គម្លាតយេនឌ័រនៅក្នុងវិស័យជលផល តាមរយៈការលើកទឹកចិត្តឲ្យស្ត្រីចូលរួមក្នុងការងារជាតំណាង និងធានាថាស្ត្រីអាចទទួលបានឱកាសក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងអប់រំ ជាពិសេសសម្រាប់ក្មេងស្រី និងយុវតីវ័យក្មេង។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានជំនាញ បទពិសោធន៍ និងធនធានមន្ត្រីដើម្បីគ្រប់គ្រង និងអនុវត្តន៍គម្រោង។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**នៅឆ្នាំ២០១៩ (ពីថ្ងៃទី១ ខែកក្កដា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩) មិនបានអនុវត្ត ដោយសារគម្រោងទើបចាប់ផ្តើម មានភាពយឺតយ៉ាវនៅក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងពេលវេលានៃការរៀបចំផែនការ និងការអនុវត្តគម្រោងត្រូវគោរពទៅតាមឆ្នាំសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា (ចាប់ផ្តើមនៅខែមករា និងបញ្ចប់នៅខែធ្នូ) ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

កម្មវិធី CAPFISH-Capture នេះ ត្រូវបានគ្រប់គ្រងដោយប្រយោលជាមួយនឹងអង្គការអន្តរជាតិដែលមានដូចខាងក្រោម៖
សមាសភាគទី១៖ ការគ្រប់គ្រង អភិរក្ស ត្រួតពិនិត្យ និងអង្កេត លើធនធានជលផលសមុទ្រ និងធនធានជលផលទឹកសាប
 ផ្នែកមួយនៃសកម្មភាពនេះគឺត្រូវបានអនុវត្តនៅក្នុងការគ្រប់គ្រងដោយប្រយោលជាមួយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (Food and Agriculture Organization - FAO) (ជាប្រធាន) និងអង្គការយូណេស្កូ (UNISCO)។
ការអនុវត្តកម្មវិធីនេះរួមចំណែកដល់៖ ១- បង្កើនសមត្ថភាពរដ្ឋបាលសាធារណៈដល់រដ្ឋបាលជលផលទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់ក្រោមជាតិ ។ ២- ពង្រឹងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងមូលនិធិសម្រាប់ការស្រាវជ្រាវវិស័យជលផល។ ៣- គាំទ្រដល់ការសម្របសម្រួលអន្តរក្រសួងសម្រាប់តំបន់ការពារដែនជីវចម្រុះបឹងទន្លេសាប ដោយផ្តល់សេវាកម្មបន្ថែមដល់សហគមន៍នេសាទ និង ៤- សម្របសម្រួលកិច្ចការសហប្រតិបត្តិការក្នុងតំបន់។
 អង្គការនេះមានសមត្ថភាពគ្រប់គ្រាន់ដើម្បីទទួលបានការងារនេះ ពីព្រោះ FAO មានបទពិសោធន៍យូរអង្វែងដែលត្រូវបានគេទទួលស្គាល់លើការងារនៅក្នុងវិស័យជលផលនៅកម្ពុជា ហើយមានជំនាញច្បាស់លាស់នៅក្នុងវិស័យនេះដែលអាចជ្រើសរើបានតាមរយៈការិយាយាល័យបរចាំតំបន់ ហើយអង្គការនេះក៏មានការិយាល័យនៅក្នុងប្រទេសកម្ពុជាផងដែរ ដែលជម្រុញឲ្យមានការសហការ គាំទ្រ និងតាមដានកាន់តែជិតស្និទ្ធ។

សមាសភាគទី២៖ ការគាំទ្រដល់ការអភិវឌ្ឍខ្សែសង្វាក់ផល ផលិតផលជលផល
ផ្នែកមួយនៃសកម្មភាពនេះគឺត្រូវបានអនុវត្តនៅក្នុងការគ្រប់គ្រងដោយប្រយោលជាមួយអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (United Nations Industrial Development Organization - UNIDO) ។ ការអនុវត្តនេះមានភាពសមហេតុផល ពីព្រោះជាលទ្ធផលនៃការអញ្ជើញឲ្យបង្ហាញចំណាប់អារម្មណ៍អំពីសហភាពអឺរ៉ុប និងអន្តរជាតិ ព្រមទាំងអណត្តិ របស់អង្គការ UNIDO ក្នុងការលើកកម្ពស់វិស័យឯកជន និងការអភិវឌ្ឍវិស័យឯកជន និងវិស័យឧស្សាហកម្មដើម្បីកាត់បន្ថយភាពក្រីក្រ ព្រមទាំងបទពិសោធន៍នៅក្នុងប្រទេសកម្ពុជាក្នុងការគាំទ្រដល់ការអភិវឌ្ឍខ្សែសង្វាក់តម្លៃជលផល។

សមាសភាគទី៣៖ ការគាំទ្រការលើកកម្ពស់ជីវភាពភាពរស់នៅ និងការធ្វើពិពិធកម្មរបស់សហគមន៍នេសាទ
 ជាជំនួយឥតសំណង ដែលអំពាវនាវឲ្យមានការដាក់ពាក្យស្នើសុំ។ សកម្មភាពដែលទទួលបានសិទ្ធិមានដូចខាងក្រោម៖
- គាំទ្រដល់ការអភិវឌ្ឍអេកូទេសចរណ៍តាមរយៈភាពជាដៃគូរវាងសហគមន៍ និងប្រតិបត្តិករឯកជន និងដើម្បីការអភិវឌ្ឍផលិតផលទេសចរណ៍ និងឱកាសការងារ
- គាំទ្រដល់គំនិតផ្តួចផ្តើមឯកជន និងសហគមន៍ ក្នុងគោលដៅបង្កើនលទ្ធភាពទទួលបានទឹកស្អាត អនាម័យ ការគ្រប់គ្រងកាកសំណល់ ថាមពល និងការផ្សាភ្ជាប់ទៅនឹងសេវាគាំទ្រអភិវឌ្ឍជនបទដែលមានស្រាប់ដូចជា សេវាកម្មបន្ថែមលើការផ្សព្វផ្សាយឯកជន និងសាធារណៈ គម្រោងអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការកសិករ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាដើម
- គាំទ្រដល់ការកែលម្អលទ្ធភាពទទួលបានពីសមាជិកសហគមន៍នេសាទទៅនឹងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំ
- ក្នុងករណីចាំបាច់ បន្ថែមលើការគាំទ្រដែលបានផ្តល់ក្នុងសមាសភាគទី១ ការគាំទ្រដល់ការអភិរក្ស/ការបង្កើតឡើងវិញនូវទីជម្រកសំខាន់ៗ (ព្រៃលិចទឹក ព្រៃកោងកាង) លទ្ធភាពនឹងត្រូវបានផ្តល់ជូនដល់គ្រួសារ និងបុគ្គលងាយរងគ្រោះ ដោយយកចិត្តទុកដាក់លើស្ត្រី យុវវ័យ និងសមាជិកក្រុមជនជាតិដើមភាគតិច។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 361.2 | 321.5 | 213.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 96.1 | 90.7 | 82.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 265.1 | 230.8 | 131.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 6,001.2 | 7,105.4 | 2,321.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 288.7 | 268.4 | 121.9 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 271.7 | 0.0 | 813.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 3,236.9 | 4,416.8 | 1,131.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 186.1 | 114.2 | 17.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 2,017.8 | 2,306.0 | 236.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 6,362.4 | 7,426.9 | 2,534.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 6,362.4 | 7,426.9 | 2,534.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| European Commission | 6,362.4 | 7,426.9 | 2,534.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 6,362.4 | 7,426.9 | 2,534.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: